**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់សាកល្បងឲ្យប្រើប្រាស់ប្រព័ន្ធទិន្នន័យ MOC CLOUD របស់ក្រសួងពាណិជ្ជកម្ម សម្រាប់បញ្ជូនឯកសារផ្ទៃក្នុងជាលក្ខណៈអេឡិចត្រូនិក

យោងសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃអាទិត្យ ៧រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ស្តីពីវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ និងដើម្បីបង្កភាពងាយស្រួលក្នុងការបញ្ជូនឯកសារពីខុទ្ទកាល័យទៅថ្នាក់ដឹកនាំ កាត់បន្ថយការប្រើប្រាស់ក្រដាសស្នាម និងជាជំនួយដល់ការធ្វើការតាមអនឡាញ (Online) ក្រសួងពាណិជ្ជកម្មសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងអគ្គាធិការ** មេត្តាជ្រាបថា៖ ក្រសួងពាណិជ្ជកម្មសម្រេចដាក់សាកល្បងឲ្យប្រើប្រាស់ប្រព័ន្ធទិន្នន័យ MOC CLOUD ជាមធ្យោបាយបញ្ជូនឯកសារផ្ទៃក្នុងជាអេឡិចត្រូនិក ពីខុទ្ទកាល័យទៅថ្នាក់ដឹកនាំ (រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងអគ្គាធិការ) ដើម្បីមុខការតាមការណែនាំរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** ហើយឯកសារទម្រង់ជាក្រដាសអាចប្រគល់ជូនក្នុងករណីចាំបាច់។ ថ្នាក់ដឹកនាំនីមួយៗ អាចធ្វើការបែងចែកឯកសារ និងធ្វើការណែនាំបន្តទៅថ្នាក់ក្រោមតាមរយៈប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត តាមលទ្ធភាពជាក់ស្តែង។ ការដាក់សាកល្បងប្រើប្រាស់ប្រព័ន្ធទិន្នន័យ MOC CLOUD សម្រាប់បញ្ជូនឯកសារអេឡិចត្រូនិកនេះ នឹងត្រូវអនុវត្តចាប់ពី**ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ នេះតទៅ។**

សម្រាប់ជំនួយបច្ចេកទេស សូមទាក់ទងមកមន្ត្រី ដូចរាយនាមខាងក្រោម៖

- លោក ម៉ិល ចាន់ថា ទូរស័ព្ទលេខ៖ ០១២ ៦៩១ ៨៧២
- លោក សួន សោភ័ណ ទូរស័ព្ទលេខ៖ ០៧៧ ៥៥៥ ០៥៣
- លោក តាំ ពិសិដ្ឋ ទូរស័ព្ទលេខ៖ ០១២ ៧៦៧ ០៤៣
- លោក អ៊ិក សុភ័ត្រា ទូរស័ព្ទលេខ៖ ០៨៩ ៣៥៥ ៦៩៦

ថ្ងៃសុក្រ ១២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thia, Sangkat Teuk Thia, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469